**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង**
**ចំប៉ា ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩**

# ឪពុកម្ដាយដែលបានស្រឡាញ់កូនជានិមិត្តរូបនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់

**អត្ថបទទី១៖ បេនស៊ីរ៉ាក ៣,១៧-១៨.២០.២៨-២៩**

អ្នកណាជួយយកអាសារអ្នកដទៃ អ្នកនោះមុខជាមានសេចក្ដីសុខសម្រាប់អនាគត ពេលមានអាសន្ន គាត់នឹងរកទីពឹងបាន។ បសរ ៣,២៩

**អត្ថបទទី២៖ ហេប្រឺ ១២,១៨-១៩.២២-២៤**

បងប្អូនចូលមកជិតព្រះយេស៊ូ ដែលជាស្ពាននៃសម្ពន្ធមេត្រី*ថ្មី ហើយចូលមកជិតព្រះលោហិតសម្រាប់ប្រោះ គឺជាព្រះលោហិតដែលទូលអង្វរ ប្រសើរជាងលោហិតរបស់លោកអេបិលទៅទៀត។ ហាប ១២,២៤

**ដំណឹងល្អ៖ លូកា ១៤,១.៧-១៤**

អ្នកណាលើកតម្កើងខ្លួន អ្នកនោះនឹងត្រូវគេបន្ទាបចុះ។ រីឯអ្នកដែលបន្ទាបខ្លួន នឹងត្រូវគេលើកតម្កើងវិញ។ លក ១៤,១១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះរំភើបនៅពេលខ្ញុំបានឃើញ ៥៣គូ ជាប្ដីប្រពន្ធដែលអង្គុយនៅមុខខ្ញុំ នេះជាការអស្ចារ្យនិងជាអំណោយទានពិសេសសម្រាប់ព្រះសហគមន៍នៅក្នុងមណ្ឌលមេគង្គ។ ពេលយើងនឹកឃើញថា យើងកំពុងអង្គុយនៅមុខធាតុសន្ត លូវីស និងសន្តី ហ្សេលី ជាពេលវេលាមួយយ៉ាងពិសេសបំផុត ដើម្បីអរព្រះគុណព្រះជាម្ចាស់។ ខ្ញុំជឿថាយើងបានរៀបការ២០ឆ្នាំ ៣០ឆ្នាំ ៤០ឆ្នាំ ៥០ឆ្នាំ ជាពេលវេលាដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឲ្យសព្វថ្ងៃយើងនៅជាមួយគ្នាតទៅទៀត ដោយសារយើងដឹងហើយនៅក្នុងពិភពលោកមានបុរសមានស្ត្រីជាច្រើន ដែលរៀបការប៉ុន្តែ២ឆ្នាំ៥ឆ្នាំក្រោយមកគេបែកគ្នា។ ប៉ុន្តែ ថ្ងៃនេះយើងមាន៥៣គូដែលបានរួមរស់ជាមួយគ្នា និងបានបង្កើតគ្រួសារដែលមានកូនយ៉ាងច្រើន ថ្ងៃនេះយើងអង្គុយនៅមុខព្រះជាម្ចាស់ និងមុខសន្តលូវីស និងសន្តី ហ្សេលី ដើម្បីអរព្រះគុណព្រះជាម្ចាស់។

ទាំង២នាក់មានម្នាក់ចង់ធ្វើជាដូនជី និងម្នាក់ទៀតចង់ធ្វើជាបូជាចារ្យ ហ្សេលី គាត់គិតថាគាត់ចង់ធ្វើបងស្រី និង លូវីស គាត់គិតថាគាត់ចង់ធ្វើបូជាចារ្យ។ នៅពេលគេចាប់ផ្ដើមរៀនធ្វើជាបងស្រី និងលោកឪពុក គេបានគិតថាគេធ្វើមិនបានដោយសារ លូវីស គាត់រៀនភាសាឡាតាំងស្ទើរ ហ្សេលី ដូចជាអត់មានការត្រាស់ហៅជាបងស្រី។ ហេតុនេះហើយ ទាំង២នាក់បានចេញនិងចាប់ផ្ដើមធ្វើការ មានថ្ងៃមួយទាំង២នាក់គេជួបគ្នានៅលើស្ពានមួយ គេដើរនិងពេលគេឃើញមុខ

គ្នាទៅវិញទៅមក គេយល់ថាគេស្រឡាញ់គ្នាហើយ។ ដូច្នេះ ខ្ញុំចង់ឲ្យ ៥៣គូ នឹកឃើញថ្ងៃដែលបានជួបគ្នាលើកទី១ ២នាក់នោះពេលជួបលើកទី១គេមើលមុខគ្នា បេះដូងលោតខ្លាំងៗហើយគេយល់ថាគេស្រឡាញ់គ្នាហើយបីខែក្រោយមកគេរៀបការ។ គេរៀបការនិងគេចាប់ផ្ដើមជីវិតជាប្ដីប្រពន្ធដោយមានគោលបំណងមួយ គេថាយើងចង់មានកូនច្រើនដោយសារយើងដឹងថាព្រះជាម្ចាស់ ណែនាំឲ្យយើងមានកូនច្រើនដើម្បីឲ្យកូនយើងស្គាល់ព្រះជាម្ចាស់ និងនៅថ្ងៃណាមួយយើងអាចរស់នៅជាមួយព្រះជាម្ចាស់បាន។

នៅទីនេះ មានកូនច្រើនណាស់កូនៗសូមមើលឪពុកម្ដាយដែលបានតស៊ូដើម្បីចិញ្ចឹម តស៊ូដើម្បីអប់រំ តស៊ូដើម្បីដឹកនាំ។ ដូចគ្រួសារសន្ត លូវីស និងសន្ដី ហ្សេលី គេចង់មានកូនច្រើនគេមានកូន៩នាក់ ប៉ុន្ដែមាន៤នាក់បានទទួលមរណភាពពេលគេនៅតូចៗ ដោយសារសម័យហ្នឹងអត់មានថ្នាំ អត់មានគ្រូពេទ្យព្យាបាល នៅសល់កូនស្រី៥នាក់ ដែលទាំង៥នាក់សុំធ្វើជាបងស្រី។ ក្នុងកូនស្រីទាំង៥ មានម្នាក់ដែលឈ្មោះសន្ដី តេរេសា នៃព្រះកុមារយេស៊ូ។ មូលហេតុដែលគ្រួសារនេះបានរស់នៅដូចនេះ ដោយសារគេយល់ថាជីវិតគេបានទទួលពីព្រះជាម្ចាស់ ដូច្នេះគេចង់ប្រគល់ជីវិតយ៉ាងច្រើន គេបានបង្កើតកូនយ៉ាងច្រើនដើម្បីរស់នៅតាមគម្រោងការណ៍របស់ព្រះជាម្ចាស់។ គេបានអប់រំកូនគេឲ្យស្រឡាញ់ព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់។ សន្ដី តេរេសា ដែលស្រឡាញ់ព្រះយេស៊ូយ៉ាងពិសេស ដែលស្រឡាញ់ព្រះជាម្ចាស់ជាព្រះបិតាយ៉ាងពិសេសបំផុត នៅពេលគាត់នឹកឃើញព្រះបិតាគាត់នឹកឃើញឪពុករបស់គាត់។ គាត់ធ្លាប់និយាយថា "**អ្វីៗទាំងអស់ដែលឪពុកខ្ញុំបានធ្វើ លើកលែងទោសឲ្យខ្ញុំ ស្រឡាញ់ខ្ញុំ លើកទឹកចិត្តខ្ញុំ ផ្ដល់ភាពកក់ក្ដៅឲ្យខ្ញុំ ខ្ញុំនឹកឃើញនេះជាព្រះបិតារបស់ខ្ញុំនៅស្ថានបរមសុខ ព្រះបិតារបស់ខ្ញុំស្រឡាញ់ខ្ញុំ ដូចឪពុកខ្ញុំ**"។

ដូច្នេះ ឪពុកម្ដាយដែលបានស្រឡាញ់កូនទៅជានិមិត្តរូបនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងជាក់ស្ដែង យើងនិយាយអំពីព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ប៉ុន្ដែនៅថ្ងៃនេះនៅពេលយើងស្ដាប់បទពិសោធន៍នៃជីវិតរបស់សន្ត លូវីស និងសន្ដី ហ្សេលី យើងយល់ថាសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មិនមែនតែជាគំនិតមួយ មិនមែនតែជាពាក្យនិយាយមួយ មិនមែនតែជាទស្សនៈមួយ ប៉ុន្ដែជាក់ស្ដែងនៅក្នុងសេចក្ដីស្រឡាញ់នៃគ្រួសារ ពេលគ្រួសារមួយចេះស្រឡាញ់គ្នា ចេះលើកទឹកចិត្តគ្នា ទោះបីមានបញ្ហាក៏ដោយ ទោះបីមានការឈ្លោះគ្នាក៏ដោយ ទោះបីមានទុក្ខលំបាកក៏ដោយ ប៉ុន្ដែយើងដឹងថាព្រះជាម្ចាស់ស្រឡាញ់យើង និងជួយយើងឲ្យយើងទៅមុខ។ ជាមូលហេតុ ២០ឆ្នាំមុន ៤០ឆ្នាំមុន ៥០ឆ្នាំមុន នៅមុខព្រះជាម្ចាស់បានក្លាយជាប្ដីប្រពន្ធនៅក្នុងអគ្គ

សញ្ញាអាពាហ៍ពិពាហ៍ និងថ្ងៃនេះអាចអង្គុយនៅមុខព្រះជាម្ចាស់តទៅទៀតដោយសារដឹងថាព្រះជាម្ចាស់ថែរក្សាជីវិតជាប្ដីប្រពន្ធ ជាគ្រួសារ។

លូវីស និង ហ្សឺលី ស្រឡាញ់ព្រះជាម្ចាស់ជាអាទិភាព រាល់ថ្ងៃម៉ោង៥កន្លះចូលអភិបូជារាល់ថ្ងៃអាទិត្យគេណែនាំឲ្យកូនៗចូលអភិបូជា។ រាល់ព្រឹក គេភ្ញាក់ពីដេកគេអធិដ្ឋានដើម្បីអរព្រះគុណព្រះជាម្ចាស់ និងសូមឲ្យព្រះអង្គថែរក្សាគ្រួសារគេនៅថ្ងៃហ្នឹង និងរាល់ពេលយប់គាត់ប្រមូលកូនស្រីទាំង៥នាក់ អង្គុយនៅមុខរូបព្រះនាងម៉ារី សន្តយ៉ូសែប និងឈើឆ្កាងរបស់ព្រះយេស៊ូ ដើម្បីអធិដ្ឋានអរព្រះគុណព្រះជាម្ចាស់សម្រាប់ពេញមួយថ្ងៃ ដែលព្រះអង្គបានប្រទានសេចក្ដីសុខ ដើម្បីសុំទោសសម្រាប់អំពើបាបដែលបានធ្វើ ដើម្បីឲ្យដេកស្រួលយ៉ាងសុខសាន្ត។ គ្រួសារដ៏វិសុទ្ធ មិនមែនដោយសារគេជាមនុស្សពិសេស ប៉ុន្តែដោយសាគេភ្ជាប់ជាមួយព្រះជាម្ចាស់នៅក្នុងសេចក្ដីស្រឡាញ់ ចូលវិហារ អធិដ្ឋាន និងអប់រំកូនៗឲ្យស្គាល់ព្រះយេស៊ូ។ នៅពេល ហ្សឺលី គាត់ពាក់អាវឲ្យកូនគាត់ គាត់និទានរឿងអំពីព្រះយេស៊ូ រឿងសន្តយ៉ូសែប អំពីព្រះនាងម៉ារី អំពីសន្តសន្តីទាំងឡាយឲ្យកូនស្គាល់។ ដូច្នេះ បន្តិចម្ដងៗកូនគេចាប់ផ្ដើមស្រឡាញ់ព្រះយេស៊ូមែនទែន ដោយសារគេស្ដាប់ពីឪពុកម្ដាយ ឪពុកម្ដាយជួយអប់រំណែនាំ។ ប៉ុន្តែ ឪពុកម្ដាយនេះមិនមែនជាឪពុកម្ដាយដែលប្លែកពីយើង ជាគ្រួសារដែលមានទុក្ខលំបាកដែរ ហ្សឺលី ពេលអាយុ៤៥ឆ្នាំគាត់ចាប់ផ្ដើមឈឺជំងឺមហារីកសុដន់ គ្រូពេទ្យថាព្យាបាលមិនបាន។ ដូច្នេះ គាត់ស្លាប់នៅអាយុ៤៦ឆ្នាំ ដែល តេរេសា មានអាយុតែ៤ឆ្នាំ ដោយទុកឲ្យកូនក្លាយជាកុមារកំព្រា៥នាក់។ លូវីស ម្នាក់ឯងគាត់យកចិត្តទុកដាក់ដើម្បីអប់រំណែនាំស្រឡាញ់កូនរបស់គាត់ បន្តធ្វើដំណើរនៅក្នុងជីវិតទោះបីប្រពន្ធឡើងស្ថានបរមសុខហើយ។

លូវីស គាត់ចូលចិត្តជក់បារីប៉ុន្តែគាត់សម្រេចចិត្តឈប់ជក់បារី ដោយសារគាត់ដឹងថាដើម្បីដើរជាមួយព្រះជាម្ចាស់ ខ្ញុំត្រូវការលះបង់។ គាត់ដឹងថា បារីអត់ល្អសម្រាប់សុខភាពគាត់ អត់ល្អសម្រាប់បងប្អូនឯទៀតៗ ដូច្នេះគាត់តាំងចិត្តដើម្បីឈប់ជក់បារីនៅក្នុងនាមស្រឡាញ់ព្រះជាម្ចាស់។ លូវីស គាត់តាំងចិត្តដើម្បីកែប្រែដោយយកចិត្តទុកដាក់ ដើម្បីឲ្យជីវិតរបស់គាត់ជាប់ជាមួយព្រះជាម្ចាស់ថែមទៀត។ គ្រួសារនេះមិនមែនជាគ្រួសារដែលប្លែកពីគ្រួសារយើងទេ ប៉ុន្តែប្លែកនៅក្នុងរបៀបដែលគេយកព្រះជាម្ចាស់ជាអាទិភាព។ ថ្ងៃនេះ ខ្ញុំឃើញមានមហាជនដែលចូលនៅក្នុងអភិបូជា ខ្ញុំយល់ថាសម្រាប់យើងក៏ដូចគ្នាដែរព្រះជាម្ចាស់ជាអាទិភាព។ ថ្ងៃនេះ វិហារយើងហៀរយើងមានមនុស្សពេញ ដោយសាយើងចង់បង្ហាញថាយើងស្រឡាញ់ព្រះម្ចាស់មែនទែន។ ជាមូលហេតុ ៥៣គូ ដែលអង្គុយនៅទីនេះ អាចមានជីវិតរហូតដល់សព្វថ្ងៃដោយសារបានធ្វើបានជីវិតទៅលើព្រះជាម្ចាស់។ នៅទីនេះ យើងបានតស៊ូច្រើនណាស់ តស៊ូនៅក្នុងជីវិត តស៊ូនៅក្នុងការ

ចិញ្ចឹមកូន តស៊ូនៅក្នុងការរស់នៅប្រចាំថ្ងៃនៅក្នុងសង្គមដែលទទួលស្វាគមន៍មិនពេញលក្ខណ តស៊ូនៅក្នុងជីវិតប្រចាំថ្ងៃមែនទែន។ យើងដឹងថា យើងអាចតស៊ូដល់កម្រិតនេះ ដោយសារយើងមានជំនឿលើព្រះជាម្ចាស់ យើងដឹងថាព្រះម្ចាស់ស្រឡាញ់យើង។

ថ្ងៃនេះ ខ្ញុំជាពេលវេលាដើម្បីអរព្រះគុណព្រះជាម្ចាស់ ដោយនឹកឃើញផ្លែយ៉ាងច្រើនដែលយើងបង្កើត ឲ្យគ្រួសារនីមួយៗនឹកឃើញ កូន១០នាក់ កូន៩នាក់ កូន៨នាក់ កូន៧នាក់ កូន៦នាក់ កូន៥នាក់ កូន៤នាក់ កូន៣នាក់ កូន២នាក់ កូនម្នាក់ នឹកឃើញផ្លែដែលយើងបានបង្កើត និងទូលអង្វរព្រះជាម្ចាស់ឲ្យកូនៗរបស់យើងបន្តជីវិតនៅក្នុងសេចក្តីសុខ។ ដូច្នេះ ថ្ងៃនេះយើងត្រូវតែអរព្រះគុណព្រះជាម្ចាស់ និងសូមឲ្យព្រះអង្គប្រទានពរឲ្យព្រះសហគមន៍របស់យើង ឲ្យទៅជាមហាគ្រួសារមួយនៅក្នុងអង្គព្រះគ្រីស្ត និងសូមសន្ត លូវីស និងសន្តី ហ្សីលី ការពារថែរក្សាគ្រួសារយើង ឲ្យយើងរកឃើញសេចក្តីសុខ នៅពេលយើងធ្លាក់ទឹកចិត្ត នៅពេលយើងឈ្លោះគ្នា នៅពេលយើងមានទុក្ខលំបាក នៅពេលយើងឈឺចាប់ យើងដឹងថាព្រះជាម្ចាស់នៅ។ នៅពេល លូវីស គាត់ចាប់ផ្តើមវង្វេងស្មារតី ពេលគាត់ដឹងខ្លួនម្តងៗគាត់ជួបជាមួយកូនស្រីគាត់ គាត់និយាយថា "**កូនអើយ! កុំព្រួយបារម្ភអំពីប៉ា ដោយសារប៉ាទោះបីឈឺក៏ដោយប៉ាដឹងថាប៉ាជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ ដូច្នេះកុំព្រួយបារម្ភឲ្យសោះ**"។ ដូច្នេះ ខ្ញុំសង្ឃឹមបងប្អូនទាំងអស់យើងជាឪពុក យើងជាម្តាយ យើងជាលោកតា យើងជាលោកយាយ យើងជាកូនៗ យើងជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ ណែនាំឲ្យយើងមានសេចក្តីក្លាហានដើម្បីទៅមុខទៀត ដើម្បីបង្កើតគ្រួសារ គ្រួសារដ៏សុខសាន្ត។ អាម៉ែន៕